

# តើអ្នកអាចប្រើឱសថអង់ទីប៊ីយ៉ូទិកដោយការទទួលខុសត្រូវក្នុងសត្វចិញ្ចឹមរបស់អ្នកដោយរបៀបណា?

## សូមចងចាំថា អ្នកអាចជួយកាត់បន្ថយតម្រូវការឱសថអង់ទីប៊ីយ៉ូទិកដោយ៖

- ការការពារជំងឺតាមរយៈការចាក់វ៉ាក់សាំងជាប្រចាំ ដោយផ្អែកលើកម្មវិធីនៃការចាក់វ៉ាក់សាំងតាមប្រភេទសត្វនិមួយៗលើសត្វចិញ្ចឹមរបស់អ្នក។
- ការថែរក្សា សត្វចិញ្ចឹមរបស់អ្នកឱ្យមានសុខភាពល្អ តាមរយៈការផ្តល់ឲ្យសត្វនូវចំណីអាហារ ដែលមានជីវជាតិ និងទឹកស្អាត។
- ការធ្វើអនាម័យ និងការសម្អាតទីកន្លែងចិញ្ចឹម ទ្រុងក្រោល ។ល។

ផលិតដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាមួយការគាំទ្រនៃអង្គការសុខភាពសត្វពិភពលោក និងការចូលរួមថវិការបស់គម្រោង AMR Multi-Partner Trust Fund

World Organisation for Animal Health
Founded as OIE

# តើឱសថអង់ទីប៊ីយ៉ូទិកជាអ្វី ?

- ឱសថអង់ទីប៊ីយ៉ូទិកគឺជាឱសថចាំបាច់សម្រាប់ព្យាបាល ជំងឺបង្កឡើងដោយបាក់តេរីលើមនុស្ស និងសត្វ ។
- នៅពេលដែលអ្នកប្រើឱសថអង់ទីប៊ីយ៉ូទិកកាន់តែច្រើនប្រសិទ្ធភាពរបស់វាកាន់តែថយចុះ។
- ការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកច្រើនហួសកំរិត និងមិនបានត្រឹមត្រូវនឹងពន្លឿនការវិវត្តនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិក (AMR)។
- នៅពេលដែលភាពស៊ាំនឹងឱសថអង់ទីប៊ីយ៉ូទិកកើតឡើងឱសថអង់ទីប៊ីយ៉ូទិកនឹងមិនមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺឆ្លងបានដូចមុនទៀតនោះទេ។



## តើអ្នកប្រើឱសថអង់ទីប៊ីយ៉ូទិកដោយទំនួលខុសត្រូវលើសត្វចិញ្ចឹមដោយរបៀបណាខ្លះ ?

- ប្រសិនបើសត្វចិញ្ចឹមរបស់អ្នកឈឺ សូមពិគ្រោះជាមួយបសុពេទ្យដែលមានការទទួលស្គាល់ ដើម្បីទទួលបានការណែនាំ និងព្យាបាលឱ្យបានសមស្រប។
- មិនត្រូវផ្តល់ឱសថអង់ទីប៊ីយ៉ូទិកដល់សត្វចិញ្ចឹមក្នុងផ្ទះរបស់អ្នកដោយគ្មានវេជ្ជបញ្ជា ដែលផ្តល់ដោយបសុពេទ្យដែលមានការទទួលស្គាល់នោះទេ។
- ត្រូវប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកឱ្យបានពេញលេញតាមវេជ្ជបញ្ជា ទោះបីជាសត្វចិញ្ចឹមរបស់អ្នកហាក់ដូចជា ធូរស្បើយពីជំងឺក៏ដោយ។
- កុំចែករំលែកឱសថអង់ទីប៊ីយ៉ូទិកជាមួយម្ចាស់សត្វចិញ្ចឹមដទៃទៀត។
- ពិនិត្យកាលបរិច្ឆេទផុតកំណត់របស់ឱសថ មុនពេលប្រើប្រាស់។ បោះចោលឱសថអង់ទីប៊ីយ៉ូទិកដែលផុតកំណត់ ក៏ដូចជាដប និងស្រោមរបស់វាឱ្យបានត្រឹមត្រូវ។

